NSW GOVERNMENT Education International

Australia FutureUnlimited

# វិទ្យាល័យ

# EAST HILLS BOYS

**សាលារដ្ឋ NSW** | **ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី**







**អាសយដ្ឋាន**
Lucas Rd
Panania NSW 2213

**គេហទំព័រ**
www.easthillsb-h.schools.nsw.edu.au

**បង្កើតឡើងឆ្នាំ**
1955

**បាវចនារបស់សាលា**
*Servio* – I serve

**ចំនួនសិស្ស**
820

**ចំងាយពីក្រុងស៊ីដនី**
21km




វិទ្យាល័យ East Hills Boys បានជ្រើសយកវិធីសាស្ត្រអប់រំរួមមួយ ដែលសិស្ស អាណាព្យាបាល គ្រូបង្រៀន និងសហគមន៍ បានខិតខំប្រឹងប្រែងដើម្បីសម្រេចបាននូវស្តង់ដារអប់រំដ៏ល្អបំផុតសម្រាប់យុវជនគ្រប់រូប។ សាលាបានចាត់ទុកការសិក្សាជាបញ្ហាអាទិភាព ដោយបង្កប់នូវខ្លឹមសារអប់រំមួយចំនួនដូចជា៖ ការប្រឹងប្រែងឲ្យសម្រេចបាននូវឧត្តមភាពផ្ទាល់ខ្លួន ការគោរពខ្លួនឯង គោរពអ្នកដទៃ និងគោរពសមាជិកគ្រប់រូបក្នុងសហគមន៍, ការបង្កើតឲ្យមានបរិយាកាសប្រកបដោយសុវត្ថិភាពនិងមានការគាំទ្រ ការទំនួលខុសត្រូវនិងរាប់រងចំពោះសកម្មភាពនិងសេចក្តីទៀងត្រង់របស់ខ្លួន ព្រមទាំងភាពស្មោះត្រង់ និងភាពជឿជាក់។

## ភាសាអង់គ្លេសជាភាសាទីពីរ (ESL)

- គ្រូជំនាញផ្នែក ESL
- ការបង្រៀនមេរៀនជាក្រុម
- ការបង្រៀនមួយនឹងមួយ

## សេវាកម្មគាំទ្រសិស្ស

- ក្រុមគាំទ្រការសិក្សា
- ឥរិយាបថវិជ្ជមានសម្រាប់ការសិក្សា
- អ្នកសម្របសម្រួលគាំទ្រការសិក្សា
- សុខុមាលភាពរបស់ប្រធានគ្រូ
- បុគ្គលិកគាំទ្រការសិក្សាក្នុងសាលា

## កម្មវិធីពិសេស

- ការបោះជំរុំនៅឆ្នាំទី7 9 និង 11
- ការប្រកួតកីឡារវាងសាលានានា
- ក្រុមតន្ត្រីសាលា ក្រុមចម្រៀង ការបង្រៀនឧបករណ៍តន្ត្រី កម្មវិធីលើកកម្ពស់ទេពកោសល្យ
- ក្រុមរាំ Wakakirri និង hip-hop
- កម្មវិធីនិងការគាំទ្រដល់អ្នកមានទេពកោសល្យ

## មជ្ឈមណ្ឌលពិសេសនានា

- ទីលានកីឡាវាយកូនបាល់ ហ្វិតសាល និងបាល់បោះ
- បន្ទប់Green-Screen និងពហុសារព័ត៌មាន
- ទីធ្លាសម្រាប់សិស្សថ្មីសិក្សា និងអាហារដ្ឋាន
- មជ្ឈមណ្ឌលកិច្ចការផ្ទះដែលមានជំនួយពីគ្រូ

**3 ហេតុផលសម្រាប់ការជ្រើសរើសសាលានេះ**

| | |
|---|---|
| 1 | ឧត្តមភាពក្នុងការអប់រំយុវជន |
| 2 | ការគាំទ្រពេញទំហឹងរបស់ ESL |
| 3 | កម្មវិធីសិក្សាចម្រុះ |

## លទ្ធផលការសិក្សា

សិស្សបញ្ចប់ការសិក្សាថ្មីៗ ទទួលបានលទ្ធផលការសិក្សាលើសពីមធ្យមភាគរបស់រដ្ឋក្នុងវគ្គសិក្សាដែលបានផ្តល់ជូន។ ជាងមួយភាគបីនៃចំនួនសិស្សទទួលបានកម្រិតសិក្សា HSC ខ្ពស់បំផុតចំនួនពីរ។ សិស្សមួយចំនួនទទួលបានចំណាត់ថ្នាក់ATAR ក្នុងកម្រិតពិន្ទុ 90 និងមានសិស្សជាច្រើនទៀតកំពុងជ្រើសយកជំនាញសម្រាប់ការសិក្សានៅសាកលវិទ្យាល័យ។

## លក្ខណៈពិសេសនៃទីតាំងក្នុងតំបន់

សាលាមានទីតាំងស្ថិតនៅ Panania ចម្ងាយ 26kms ខាងត្បូងឈាងខាងលិចនៃ Sydney CBD នៅជិតឧទ្យានជាតិ Georges River ។តំបន់នេះមានឧទ្យានសាធារណៈ និងមជ្ឈមណ្ឌលនានារួមមាន៖

- អាងទឹក Revesby
- Revesby PCYC
- សភាក្រុមប្រឹក្សា Bankstown
- មជ្ឈមណ្ឌលកីឡា Crest Athletics Center
- មជ្ឈមណ្ឌលសិល្បៈ Bankstown

www.internationalschool.edu.au